**The City of Seattle**

Gregory J. Nickels, Mayor

# ច្បាប់សំរាប់ប្រើកុំព្យូទ័រសាធារណៈ

*សាលាក្រុង Seattle ផ្តល់ឲ្យចូលប្រើកុំព្យូទ័រជាសាធារណៈដើម្បីធានាថា គ្រប់ពលរដ្ឋទាំងអស់អាចបានទទួលការបំរើពីរដ្ឋាភិបាល និងទទួលធនធានសំខាន់ៗដទៃផ្សេងទៀត, ដើម្បីលើកទឹកចិត្តឲ្យពលរដ្ឋចូលរួម និងដើម្បីបង្កើនឲ្យចេះអាន និងសរសេរតាមរយៈបច្ចេកទេស។*




*សូមជួយយើងឲ្យនៅបន្តផ្តល់ប្រយោជន៍ជាសាធារណៈនេះតទៅទៀត ដោយធ្វើតាមច្បាប់ទាំងនេះ ហើយនិងជួយជំរុញជនដទៃឲ្យធ្វើតាមដូច្នេះដែរ។*

1. <u>យល់ពីច្បាប់ទាំងអស់:</u> អ្នកត្រូវទទួលខុសត្រូវសំរាប់ការអាន និងយល់នូវច្បាប់ទាំងនេះ។ បើអ្នកមិនយល់ច្បាប់ទាំងនេះទេ ចូរសួរបុគ្គលិកដើម្បីជួយអ្នក។ អ្នកអាចទូរស័ព្ទទៅក្រសួងព័ត៌មានបច្ចេកទេសតាមលេខ 684-0600 ឬអ៊ីមែល publiccomputers@seattle.gov ។ យើងនឹងជួយអ្នកក្នុងភាសារបស់អ្នកផ្ទាល់ជាមួយនឹងអ្នកបកប្រែភាសាម្នាក់តាមការស្នើ។

<u>2, ច្បាប់នៃអាគារក៏អនុវត្តដែរ:</u> ច្បាប់នៃឥរិយាបថសំរាប់អាគារក្រុងក៏ត្រូវអនុវត្តដើម្បីប្រើកុំព្យូទ័រដែរ។ បុគ្គលិកក្រុងអាចឲ្យអនុវត្តច្បាប់ទាំងអស់នេះ។

<u>3 ការបញ្ចូលឈ្មោះប្រើក្នុងកុំព្យូទ័រ:</u> អ្នកត្រូវតែបញ្ចូលឈ្មោះ “log-on” ទៅក្នុងកុំព្យូទ័រ នឹងបញ្ចេញពីកុំព្យូទ័រ “log-off” នៅពេលឈប់ប្រើ។ នេះគឺជាការការពាររបស់អ្នក។ វាអាចនឹងជួយលុបព័ត៌មានផ្ទាល់ខ្លួនណាមួយដែលនៅសល់ក្នុងកុំព្យូទ័រនៅពេលប្រើអ៊ីមែលឬការចូលទៅមើលក្នុងគេហទំព័រទាំងឡាយ។

<u>4. មានពេលកំណត់:</u> គឺមានកំណត់សំរាប់ថាតើរយៈពេលប៉ុន្មានអ្នកអាចប្រើកុំព្យូទ័រ។ នៅក្នុងរយៈកំណត់ពេលរបស់អ្នកត្រូវចប់ អ្នកត្រូវតែអនុញ្ញាតឲ្យអ្នកនៅក្នុងជួរបន្ទាប់ប្រើកុំព្យូទ័រម្តង។ អាទិភាពអាចត្រូវប្រគល់ទៅឲ្យជនដែលប្រើកុំព្យូទ័រដើម្បីរកព័ត៌មាននៃរដ្ឋ, មានសកម្មភាពទាក់ទងរកការងារធ្វើ, ចូលក្រសួងសង្គមកិច្ចនឹងសុខាភិបាល ឬបើគេប្រើវាសំរាប់ក្នុងគោលបំណងការអប់រំឬផ្នែកសិទ្ធិពលរដ្ឋ។

<u>5. កុំព្យូទ័រគឺមានតំរងព័ត៌មាន:</u> ប្រជាជនជាច្រើនប្រើអាគារនេះ, ដោយរួមទាំងកុមារទាំងអស់ផងដែរ។ កុំព្យូទ័រទាំងអស់គឺមានកម្មវិធីច្រោះព័ត៌មានដើម្បីជួយធានាឲ្យមានសុវត្ថិភាពបរិស្ថាន។ ករណីនេះគឺកំរិតនូវសេចក្តីអត្ថបទអ្វីដែលអាចមាននៅក្នុងអ៊ិនធឺណិត។ ព័ត៌មានច្រើនថែមទៀតអំពីរឿងនេះ គឺមាននៅក្នុងអ៊ិនធឺណិត www.seattle.gov/tech/public.htm ។

<u>6, ចូររក្សាកន្លែងឲ្យស្អាត:</u> អ្នកត្រូវតែរក្សាកន្លែងឲ្យបានស្អាត។ អាហារ, ភេសជ្ជៈឬស្ករគ្រាប់មិនអនុញ្ញាតឲ្យយកចូលកន្លែងកុំព្យូទ័រទេ។

<u>7. ចូរកុំសាកបញ្ចូលកម្មវិធី SOFTWARE ឬដូរកុំព្យូទ័រ:</u> មិនអនុញ្ញាតឲ្យអ្នកប្តូរកម្មវិធីនៃកុំព្យូទ័រ ( configuration of the computer) ទេ។ កុំផ្ទេរបញ្ចូលកម្មវិធីទន់នៃកុំព្យូទ័រ (software) ឬបញ្ចូលកម្មវិធីថ្មី (new programs) ទៅក្នុងកុំព្យូទ័រឡើយ។ បើអ្នកគិតថាកម្មវិធីគួរត្រូវបញ្ចូល សូមទាក់ទងទៅបុគ្គលិកឬអ៊ីមែល communitytechnology@seattle.gov

<u>8. ចូរកុំប្រើកុំព្យូទ័រនេះដើម្បីធ្វើទុក្ខទោសដល់អ្នកដទៃ:</u> កុំព្យូទ័រទាំងនេះមិនអាចត្រូវប្រើដើម្បីរុកគួនរំខានឬគំរាមទៅអ្នកដទៃ, ផ្ញើអ៊ីមែលធ្វើការជួញដូរ, ផ្ញើធ្វើឲ្យខូចកុំព្យូទ័រដទៃ, ឬដឹកនាំសកម្មភាពខុសច្បាប់។

<u>9. យើងមិនធានាខុសត្រូវទេ:</u> សាលាក្រុងមិនធានាថាកុំព្យូទ័រឬសេវាអ៊ិនធឺណិតទាំងអស់ ថាតែងតែនឹងដើរជានិច្ចនោះទេ។ ការប្រើប្រាស់កុំព្យូទ័រសាធារណៈ និងការចូលអ៊ិនធឺណិតគឺជាកិច្ចការអ្នកផ្ទាល់។ សាលាក្រុងមិនទទួលខុសត្រូវសំរាប់ការបាត់បង់ទិន្នន័យឬការខូចខាតដែលអាចកើតមាន ដូចជាការខូចថាសស៊ីឌីជាដើមនោះទេ។

<u>10. ការខូចខាតប្រថុយនឹងអ៊ិនធឺណិតគឺជារបស់អ្នក:</u> កុំព្យូទ័រទាំងអស់អាចផ្តល់ឲ្យចូលអ៊ិនធឺណិត។ សាលាក្រុងមិនទទួលខុសត្រូវសំរាប់សេចក្តីក្នុងអត្ថបទនៃអ៊ិនធឺណិតទេ។

<u>11. អ្នកអាចបាត់បង់សិទ្ធិប្រើប្រាស់បើអ្នកបំពាននឹងច្បាប់ទាំងនេះ:</u> បើអ្នកបំពានលើច្បាប់នានា អ្នកអាចត្រូវគេបញ្ឈប់មិនឲ្យប្រើកុំព្យូទ័រ ឬអ្នកប្រហែលត្រូវគេបង្ខំឲ្យចាកចេញពីកន្លែងកុំព្យូទ័រឬអាគារ។ លទ្ធផលផ្សេងទៀតអាចទទួលទោសត្រឹមត្រូវតាមផ្លូវច្បាប់។